ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សាលាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ២៦៣/១៩-៤-២០១០
**សាលដីកា**
លេខ៧០ក្រV/យេ
ចុះថ្ងៃទី០៤-១២-២០១៣

**គោរពនាមប្រជារាស្ត្រខ្មែរ**
**សាលាឧទ្ធរណ៍**

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ដែលប្រកាសឲ្យប្រើតាមក្រឹត្យលេខ០៦ក្រចុះថ្ងៃទី០៩-០២-១៩៩៣ បើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍កាលពីថ្ងៃទី២១-១១-២០១៣ដែលមានសមាសភាពដូចតទៅ៖

**សមាសភាពក្រុមប្រឹក្សាជំនុំជំរះ**

**លោក [redacted] ប្រធាន**

**លោក [redacted] ចៅក្រមប្រឹក្សា**

**លោក [redacted] ចៅក្រមប្រឹក្សា**

**តំណាងមហាអយ្យការ**

**លោក [redacted]**

**ក្រឡាបញ្ជី**

**លោកស្រី [redacted]**

ដើម្បីជំនុំជំរះលើបណ្តឹងឧទ្ធរណ៍នៃសំណុំរឿងព្រហ្មទណ្ឌលេខ២៦៣ចុះថ្ងៃទី១៩-៤-២០១០រវាង៖

**១-ជនជាប់ចោទឈ្មោះ [redacted] គន(ដើមបណ្តឹងឧទ្ធរណ៍)**ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរ កើតនៅភូមិកែវស្លា ឃុំព្រៃឃ្នេស ស្រុកមេសាង ខេត្តព្រៃវែង មានទីលំនៅសព្វថ្ងៃបន្ទប់ជួលលេខ[redacted]វង្គ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted](រ) ម្តាយឈ្មោះ[redacted](រ)ប្រពន្ធឈ្មោះ[redacted] មានកូន២នាក់ ។ ទោសពីមុនគ្មាន ។<u>ឃុំខ្លួនថ្ងៃទី១៥.៩.២០០៩</u>។**មានមេធាវី [redacted] ហួឡាយ ការពារ**។



ផ្លូវលេខ៦ មុខសុធារស សាលាឧទ្ធរណ៍-មហាអយ្យការ (ទល់មុខព្រះបរមរាជវាំង ក្នុងបរិវេណក្រសួងយុត្តិធម៌)

**២-ជនជាប់ចោទឈ្មោះ** [redacted] **ភ័ណ្ឌ(ដើមបណ្តឹងឧទ្ធរណ៍)**ភេទប្រុស អាយុ ២៩ឆ្នាំ ជាតិខ្មែរ កើតនៅភូមិកែវស្លា ឃុំព្រៃឃ្នេស ស្រុកមេសាង ខេត្តព្រៃវែង មានទីលំនៅសព្វថ្ងៃ[redacted] ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted](រ) ម្តាយឈ្មោះ[redacted] (រ)ប្រពន្ធឈ្មោះ[redacted]មានកូន១នាក់ ទោសពីមុនគ្មាន។<u>ឃុំខ្លួនថ្ងៃទី១៥.៩.២០០៩</u>។**មានមេធាវី**[redacted]**ចបុល ការពារ.**

ជាប់ចោទពីបទ ប្លន់ និង ប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២២-៧-២០០៩ បទល្មើសដែលចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៦នៃច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ និង មាត្រា២០ នៃច្បាប់ស្តីពីការគ្រប់គ្រងគ្រឿងផ្ទុះ និង គ្រាប់រំសេវ។

**-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ** [redacted] **វ៉ាន់នី(ដើមបណ្តឹងឧទ្ធរណ៍)**ភេទស្រី អាយុ៥២ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃនៅផ្ទះលេខ៦០០អ៊ី ផ្លូវលេខ៥៩៨ សង្កាត់ស្វាយប៉ាក ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

**បានឃើញ**ពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០៩-៣-២០១០របស់ឈ្មោះ[redacted] ភ័ណ្ឌ និង បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៥-៣-២០១០របស់ឈ្មោះ[redacted]កន មិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ២៨កប៥/២៥.០២.២០១០សាលាដំបូងរាជធានីភ្នំពេញ គ្រង់ចំណុចសេចក្តីសំរេចទាំងមូល។

**<u>៦ដំណើររឿងមានដូចតទៅៈ</u>**

កាលពីថ្ងៃទី២២-៧-២០០៩វេលាម៉ោង១៦ម៉៣៩នាទី នៅចំណុចសង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញមានករណីប្លន់(ម៉ូតូ) និង ប្រើប្រាស់អាវុធខុសច្បាប់១កើតឡើងទៅលើជនរងគ្រោះឈ្មោះ[redacted] វ៉ាន់នី នៅពេលដែលកំពុងជិះម៉ូតូម៉ាក់សេ១២៥ ពណ៌ខ្មៅ សេរី២០០៨ ចេញពីផ្ទះមកតាមផ្លូវទួលសង្កែ ជិតផ្លូវលេខ២៧៣ ស្រាប់តែមានជនល្មើស២នាក់ជិះម៉ូតូមកកៀរជនរងគ្រោះឲ្យឈប់ ហើយជនល្មើសឈ្មោះ[redacted]ភ័ណ្ឌ ជាអ្នកកាន់កាំភ្លើងខ្លីភ្ជង់យកម៉ូតូ និង ឆក់យកខ្សែកពីជនរងគ្រោះ ឯឈ្មោះ[redacted]កន ជាអ្នកចុះទៅរុញជនរងគ្រោះចេញពីម៉ូតូ រួចជិះគេចខ្លួនទៅបាត់។

**បានឃើញ**សាលក្រមព្រហ្មទណ្ឌលេខ២៨កប៥/២៥.០២.២០១០សាលាដំបូងរាជធានីភ្នំពេញសំរេចសេចក្តីដូចតទៅៈ

១.ផ្តន្ទាទោសៈ

ក-ឈ្មោះ[redacted] កន ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរ.

ខ-ឈ្មោះ[redacted]ភ័ណ្ឌ ភេទប្រុស អាយុ២៩ឆ្នាំ ជាតិខ្មែរ.

ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់ចំនួន៥ឆ្នាំ(ប្រាំឆ្នាំ)បន្តពីសាលក្រមមុន និង ពិន័យជាប្រាក់ក្នុងម្នាក់ៗចំនួន៥០០.០០០៛(ប្រាំសិបម៉ឺនរៀល) ពីបទ ប្លន់ និង ប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២២-

៧-២០០៩ បទល្មើសដែលចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៦នៃច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ និង មាត្រា២០ នៃច្បាប់ស្តីពីការគ្រប់គ្រងគ្រឿងផ្ទុះ និង គ្រាប់រំសេវ។

២-បង្គាប់ឲ្យឈ្មោះ [redacted] ភ័ណ្ឌ និង ឈ្មោ [redacted] កន សងសំណងជាប្រាក់ចំនួន៥.០០០.០០០៛(ប្រាំលានរៀល)ទៅឲ្យឈ្មោះ [redacted] ភ័ន្ទនី ជាដើមបណ្តឹងរដ្ឋប្បវេណី គិតពីថ្ងៃសាលក្រមនេះចូលជាស្ថាពរ។

៣-សាលក្រមនេះជំនុំជំរះជាសាធារណៈនៅថ្ងៃទី០៥-០២-២០១០ និង ប្រកាសជាសាធារណៈនៅថ្ងៃទី២៥-០២-២០១០ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] កន ឈ្មោះ [redacted] ភ័ណ្ឌ និង មេធាវី ការពារជនជាប់ចោទ កំបាំងមុខជនរងគ្រោះ បើកផ្លូវប្តឹងទាស់ និង ឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

**បានឃើញ**ពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០៩-៣-២០១០របស់ឈ្មោ [redacted] ភ័ណ្ឌ និង បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៥-៣-២០១០របស់ឈ្មោះ [redacted] កន មិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ២៨កប៥/២៥.០២.២០១០របស់សាលាដំបូងរាជធានីភ្នំពេញ គ្រង់ចំណុចសេចក្តីសំរេចទាំងមូល។

បានឃើញរបាយការណ៍របស់សាលាឧទ្ធរណ៍.

បានឃើញសេចក្តីសន្និដ្ឋានរបស់មហាអយ្យការសាលាឧទ្ធរណ៍។

## <u>នាពេលសវនាការ</u>

ចៅក្រមអានរបាយការណ៍.

*ជនជាប់ចោទឈ្មោះ* [redacted] *កន ឆ្លើយថា៖* ខ្លួនមានមេធាវី [redacted] ហ្វូឡាយការពារ។ ខ្លួនកើតនៅភូមិកែវស្លា ឃុំព្រៃឃ្នេស ស្រុកមេសាង ខេត្តព្រៃវែង មានទីលំនៅសព្វថ្ងៃ បន្ទប់ជួលលេខ១ [redacted] ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ)ប្រពន្ធឈ្មោ [redacted] មានកូន២នាក់ ។ទោសពីមុនគ្មាន។ឃុំខ្លួនថ្ងៃទី១៥.៩.២០០៩។ខ្លួនប្តឹងឧទ្ធរណ៍ ព្រោះខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់ទេ។ខ្លួនពុំបានឆ្លើយសារភាពទេ គឺសមត្ថកិច្ចបង្ខំឲ្យខ្លួនឆ្លើយ និង បង្ខំឲ្យខ្លួនផ្តិតមេដៃ បើខ្លួនមិនធ្វើតាមសមត្ថកិច្ចៗនឹងធ្វើទារុណកម្មលើខ្លួន។ពេលកើតហេតុ ខ្លួនកំពុងរត់ម៉ូតូឌុប។សំណូមពរសុំតុលាការលើកលែងទោសឲ្យខ្លួនផង។

*ជនជាប់ចោទឈ្មោះ* [redacted] *ភ័ណ្ឌ ឆ្លើយថា៖* ខ្លួនមានមេធាវី [redacted] គឹមសេង និង [redacted] ហ្វូឡាយ ការពារ។ ខ្លួនកើតនៅភូមិកែវស្លា ឃុំព្រៃឃ្នេស ស្រុកមេសាង ខេត្តព្រៃវែង មានទីលំនៅសព្វថ្ងៃ [redacted] ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោ [redacted] (រ)ប្រពន្ធឈ្មោ [redacted] មានកូន១នាក់ ទោសពីមុនគ្មាន។ឃុំខ្លួនថ្ងៃទី១៥.៩.២០០៩។ខ្លួនប្តឹងឧទ្ធរណ៍ ព្រោះខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់ទេ។ខ្លួនពុំបានឆ្លើយសារភាពទេ គឺសមត្ថកិច្ចបង្ខំឲ្យខ្លួនឆ្លើយ និង បង្ខំឲ្យខ្លួនផ្តិតមេដៃ បើខ្លួនមិនធ្វើតាមសមត្ថកិច្ចៗនឹងធ្វើទារុណកម្មលើខ្លួន។សំណូមពរសុំតុលា

ការលើកលែងទោសឲ្យខ្លួនផង។

*ក្រឡាបញ្ជីអានចំលើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ* [redacted] *ភ័ន់នី.*

*តំណាងមហាអយ្យការសន្និដ្ឋានថា៖* ពុំមានភស្តុតាងណាមួយដែលបញ្ជាក់ថាប៉ូលីសបានធ្វើទារុណកម្មលើជនជាប់ចោទឈ្មោះ [redacted] ភ័ណ្ឌ និង ឈ្មោះ [redacted] កនទេ។តាមចំលើយរបស់សមត្ថកិច្ចបានឆ្លើយថា ពុំបានធ្វើទារុណកម្មលើជនជាប់ចោទទេ។សំអាងហេតុ និង សេចក្តីសំរេចនៃសាលក្រមមានលក្ខណៈត្រឹមត្រូវហើយ។សុំសំរេចតំកល់សាលក្រមព្រហ្មទណ្ឌលេខ២៨កប៥/២៥.០២.២០១០សាលាដំបូងរាជធានីភ្នំពេញទុកជាបានការដដែល។

*មេធាវី* [redacted] *ហុឡាយ សន្និដ្ឋានថា៖*ខ្លួនជាមេធាវីការពារឲ្យឈ្មោះ [redacted] កន ។កូនក្តីខ្លួនបានឆ្លើយបដិសេធរួចហើយថា ពុំបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ព្រោះថ្ងៃកើតហេតុនោះ កូនក្តីខ្លួនកំពុងរត់ម៉ូតូឌុប។កូនក្តីខ្លួនប្តឹងឧទ្ធរណ៍ ព្រោះគាត់ពុំបានប្រព្រឹត្តដូចការចោទប្រកាន់ទេ។កូនក្តីខ្លួនពុំបានសារភាពទេ គឺសមត្ថកិច្ចបង្ខំឲ្យគាត់ឆ្លើយ និង បង្ខំឲ្យផ្តិតមេដៃ បើកូនក្តីខ្លួនមិនធ្វើតាមសមត្ថកិច្ចៗនឹងធ្វើទារុណកម្មលើកូនក្តីខ្លួន។សំណូមពរសុំតុលាការលើកលែងទោសឲ្យកូនក្តីខ្លួនផង។

*មេធាវី* [redacted] *វិបុល សន្និដ្ឋានថា៖*ខ្លួនជាមេធាវីការពារឲ្យឈ្មោះ [redacted] ភ័ណ្ឌ ។កូនក្តីខ្លួនបានឆ្លើយបដិសេធរួចហើយថា ពុំបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ។កូនក្តីខ្លួនប្តឹងឧទ្ធរណ៍ ព្រោះគាត់ពុំបានប្រព្រឹត្តដូចការចោទប្រកាន់ទេ។កូនក្តីខ្លួនពុំបានសារភាពទេ គឺសមត្ថកិច្ចបង្ខំឲ្យគាត់ឆ្លើយ និង បង្ខំឲ្យផ្តិតមេដៃ បើកូនក្តីខ្លួនមិនធ្វើតាមសមត្ថកិច្ចៗនឹងធ្វើទារុណកម្មលើកូនក្តីខ្លួន។សំណូមពរសុំតុលាការលើកលែងទោសឲ្យកូនក្តីខ្លួនផង។

ក្រោយពីបានស្តាប់ចំលើយជនជាប់ចោទ.

ក្រោយពីបានស្តាប់អំណានចំលើយដើមបណ្តឹងរដ្ឋប្បវេណី.

ក្រោយពីបានស្តាប់តំណាងមហាអយ្យការសន្និដ្ឋាន.

ក្រោយពីបានស្តាប់មេធាវីសន្និដ្ឋានការពារ.

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ.

## <u>សភាព្រហ្មទណ្ឌ យល់ឃើញថា</u>

១-បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០៩-៣-២០១០របស់ឈ្មោះ [redacted] ភ័ណ្ឌ និង បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៥-៣-២០១០របស់ឈ្មោះ [redacted] កន មិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ២៨កប៥/២៥.០២.២០១០សាលាដំបូងរាជធានីភ្នំពេញ ធ្វើឡើងក្នុងកំណត់ច្បាប់ តាមមាត្រា៣៨២នៃក្រមនីតិវិធីព្រហ្មទណ្ឌ សាលាឧទ្ធរណ៍អាចទទួលជំនុំជំរះបាន.

២-ជនជាប់ចោទទាំង២រូបបានឆ្លើយបដិសេធនូវអំពើប្រព្រឹត្តរបស់ខ្លួន។តែតាមចំ-លើយរបស់ជនជាប់ចោទទាំង២នាក់បានឆ្លើយសារភាពនៅមុខសមត្ថកិច្ចថា កាលពីថ្ងៃទី២២-៧-២០០៩វេលាម៉ោង១៦ម៉៣៩នាទី នៅចំណុចសង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ពួកខ្លួនពិតជាបានធ្វើសកម្មភាពប្លន់ម៉ូតូសេ១២៥ ពណ៌ខ្មៅ សេរី២០០៨

ប្រាកដមែន។ចំលើយសារភាពនេះមានលក្ខណៈស៊ីសង្វាក់ទៅនឹងចំលើយជនរងគ្រោះ។ អាចឲ្យតុលាការពិចារណាបាន។

៣-រឿងក្តីនេះសាលាដំបូងបានលើកសំអាងហេតុមកបញ្ជាក់មានលក្ខណៈត្រឹមត្រូវហើយ ហេតុនេះសាលាឧទ្ធរណ៍ឯកភាពតាមសំអាងហេតុនេះទាំងស្រុង ពុំចាំបាច់លើកយកសំអាងហេតុដដែលមកបញ្ជាក់ជាថ្មីទៀតទេ។

៤-សាលក្រមព្រហ្មទណ្ឌលេខ២៨កប៥/២៥.០២.២០១០របស់សាលាដំបូងរាជធានីភ្នំពេញ សំរេចសេចក្តីមានលក្ខណៈត្រឹមត្រូវហើយ គួរតំកល់ទុកជាបានការដដែល។

ហេតុដូច្នេះ

**វិនិច្ឆ័យសេចក្តី**

**១**-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០៩-៣-២០១០របស់ឈ្មោ[redacted] និង បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៥-៣-២០១០របស់ឈ្មោ[redacted] កន ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

**២**-តំកល់សាលក្រមព្រហ្មទណ្ឌលេខ២៨កប៥/២៥.០២.២០១០របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល។

**៣**-បន្តការឃុំខ្លួនជនជាប់ចោទតាមច្បាប់។

**៤**-សាលដីកានេះប្រកាសជាសាធារណៈនៅថ្ងៃទី០៤-១២-២០១៣ ចំពោះមុខមេធាវី និង ជនជាប់ចោទ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី។

បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និង កងកំលាំងប្រដាប់អាវុធគ្រប់ដំណែងជួយសហការអនុវត្តសាលដីកានេះឲ្យបានសំរេច បើមានសំណូមត្រូវតាមច្បាប់។**

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជំរះ** |
| --- | --- | --- |
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| [redacted] | [redacted] | [redacted] |

បានថតចំលងត្រឹមត្រូវតាមច្បាប់ដើម

សាលាឧទ្ធរណ៍,ថ្ងៃទី ១១ ខែ០២ ឆ្នាំ២០១៤

**បានឃើញ**

**ប្រធានសាលាឧទ្ធរណ៍**

[redacted]

**ក្រឡាបញ្ជី**

[redacted]